**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៤ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលបៀវត្សមូលដ្ឋាននិងការបើកផ្តល់បៀវត្ស ដល់យោធិននៃកងយោធពលខេមរភូមិន្ទ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការកែសំរួលប្រព័ន្ធបៀវត្សរបស់កងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

### សម្រេច

**មាត្រា១ .-**

អនុក្រឹត្យនេះ មានគោលបំណងដើម្បីរៀបចំការកំណត់បៀវត្សមូលដ្ឋាន និង ការបើកផ្តល់បៀវត្សប្រចាំខែដល់យោធិននៃកងយោធពលខេមរភូមិន្ទ។

**មាត្រា២ ._**

អនុក្រឹត្យនេះ មានគោលដៅកំណត់៖

- កម្រិតសន្ធស្សន៍បៀវត្សមូលដ្ឋានរបស់យោធិននៃកងយោធពលខេមរភូមិន្ទ
- ការបើកផ្តល់បៀវត្សប្រចាំខែរបស់យោធិនតាមប្រព័ន្ធធនាគារ លើកលែងយោធិនដែលមានការអនុញ្ញាតដោយឡែកដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ។

**មាត្រា៣ ._**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ។

**មាត្រា៤ ._**

បៀវត្សមូលដ្ឋានរបស់យោធិននៃកងយោធពលខេមរភូមិន្ទ ត្រូវបានរៀបចំបែងចែកតាមលំដាប់នៃឋានន្តរស័ក្តិនិងត្រូវបានផ្តល់នូវកម្រិតសន្ធស្សន៍ ដូចមានកំណត់ក្នុងតារាងខាងក្រោម៖

| ល.រ | ឋានន្តរស័ក្តិ | | កម្រិតសន្ធស្សន៍បៀវត្សមូលដ្ឋាន |
|---|---|---|---|
| ១ | នាយឧត្តមសេនីយ៍ | នាយឧត្តមនាវី | ៥៥០ |
| ២ | ឧត្តមសេនីយ៍ឯក | ឧត្តមនាវីឯក | ៥៣១ |
| ៣ | ឧត្តមសេនីយ៍ទោ | ឧត្តមនាវីទោ | ៥១៣ |
| ៤ | ឧត្តមសេនីយ៍ត្រី | ឧត្តមនាវីត្រី | ៤៩៦ |
| ៥ | វរសេនីយ៍ឯក | វរនាវីឯក | ៤៧៩ |
| ៦ | វរសេនីយ៍ទោ | វរនាវីទោ | ៤៦១ |
| ៧ | វរសេនីយ៍ត្រី | វរនាវីត្រី | ៤៤៣ |
| ៨ | អនុសេនីយ៍ឯក | អនុនាវីឯក | ៤០៧ |
| ៩ | អនុសេនីយ៍ទោ | អនុនាវីទោ | ៣៨០ |
| ១០ | អនុសេនីយ៍ត្រី | អនុនាវីត្រី | ៣៤៤ |
| ១១ | នាយចំណង់ | នាយនាវីចំណង់ | ៣៣១ |
| ១២ | ព្រឹន្ទបាលឯក | នាយចក្របាលឯក | ៣១៨ |
| ១៣ | ព្រឹន្ទបាលទោ | នាយចក្របាលទោ | ៣០០ |
| ១៤ | ពលបាលឯក | ចក្របាលឯក | ២៨៤ |
| ១៥ | ពលបាលទោ | ចក្របាលទោ | ២៧៤ |
| ១៦ | ពលបាលត្រី | ចក្របាលត្រី | ២៦៥ |
| ១៧ | នាយឯក | ចក្របាលរងឯក | ២៥០ |
| ១៨ | នាយទោ | ចក្របាលរងទោ | ២៤៥ |
| ១៩ | ពលឯក | នាវិកឯក | ២៤០ |
| ២០ | ពលទោ | នាវិកទោ | ២៣៥ |

កម្រិតសន្ធស្សន៍បៀវត្សមូលដ្ឋានខាងលើ ត្រូវចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥។

**មាត្រា៥ ._**

តម្លៃឯកតាសន្ទស្សន៍សម្រាប់អនុវត្តនិងការកែប្រែតម្លៃឯកតាសន្ទស្សន៍ ត្រូវអនុវត្តតាមអនុក្រឹត្យស្តីពីតម្លៃឯកតានៃសន្ទស្សន៍សម្រាប់បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល។

**មាត្រា៦ ._**

យោធិនដែលមានសិទ្ធិទទួលបៀវត្សប្រចាំខែ ត្រូវស្ថិតក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- កំពុងបំពេញការងារក្នុងកងយោធពលខេមរភូមិន្ទ
- កំពុងផ្លាស់ប្តូរកន្លែងធ្វើការនិងកំពុងធ្វើដំណើរទៅកាន់មុខតំណែងនៅក្នុងឬក្រៅប្រទេស
- កំពុងបំពេញការសិក្សាក្នុងឬក្រៅប្រទេសតាមតម្រូវការរបស់កងទ័ព
- យោធិនពលី ពិការ មរណៈ និវត្តជន បាត់បង់សមត្ថភាពការងារដែលមិនទាន់ផ្ទេរទៅឱ្យក្រសួងទទួលបន្ទុកអតីតយុទ្ធជនគ្រប់គ្រងបន្ត
- យោធិនដែលទទួលការអនុញ្ញាតច្បាប់ក្នុងធុរៈផ្ទាល់ រយៈពេលសម្រាកព្យាបាលជម្ងឺ និងបាត់ខ្លួនក្នុងបេសកកម្ម។

**មាត្រា៧ ._**

ការបញ្ឈប់ការបើកផ្តល់បៀវត្សប្រចាំខែ ត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ក្នុងករណីដូចខាងក្រោម៖

- យោធិនដែលសុំលាឈប់ពីការងារដោយមានការអនុញ្ញាត
- យោធិនដែលមានប្រកាសបណ្តេញចេញពីកងយោធពលខេមរភូមិន្ទ
- យោធិនដែលអវត្តមានគ្មានការអនុញ្ញាតឬហួសកំណត់ដោយសម្អាងលើប្រធានស័ក្តិដែលមិនសមស្រប
- យោធិនពលី ពិការ មរណៈ និវត្តជន បាត់បង់សមត្ថភាពការងារដែលបានផ្ទេរទៅឱ្យក្រសួងទទួលបន្ទុកអតីតយុទ្ធជនគ្រប់គ្រងបន្តរួចហើយ
- យោធិនដែលបាត់បង់ឋានន្តរស័ក្តិតាមសាលក្រមឬសាលដីកាស្ថាពររបស់តុលាការ។

**មាត្រា៨ ._**

របបឧបត្ថម្ភផ្សេងៗរបស់យោធិនក្រៅពីបៀវត្សមូលដ្ឋាន ត្រូវបន្តអនុវត្តរហូតដល់មានការកែប្រែជាថ្មី។

**មាត្រា៩ ._**

បៀវត្សប្រចាំខែរបស់យោធិន ត្រូវបើកផ្តល់តាមប្រព័ន្ធធនាគារ។ ក្រសួងការពារជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ត្រូវសហការរៀបចំការបើកផ្តល់បៀវត្សប្រចាំខែដល់យោធិនតាមប្រព័ន្ធធនាគារស្របតាមលទ្ធភាពសេវារបស់ធនាគារនិងស្ថានភាពជាក់ស្តែងរបស់កងឯកភាពនីមួយៗ។

**មាត្រា១០ ._**

អនុក្រឹត្យលេខ១៨៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការកែសម្រួលប្រាក់បៀវត្សមូលដ្ឋានរបស់កងយោធពលខេមរភូមិន្ទ ត្រូវទុកជានិរាករណ៍។

**មាត្រា១១ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ [illegible] ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

| **រដ្ឋមន្ត្រីក្រសួងការពារជាតិ** | **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | **រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ** |
|---|---|---|
| **ទៀ បាញ់** | **អូន ព័ន្ធមុនីរ័ត្ន** | **ពេជ្រ ប៊ុនធិន** |

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ